**ស្ថានទូតអូស្ត្រាលី**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤

## ការប្រារព្ធខួបទី៣០ឆ្នាំ នៃកម្មវិធីអាហារូបករណ៍អូស្ត្រាលី

ថ្ងៃនេះ ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលី រួមជាមួយ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានប្រារព្ធខួបទី៣០ឆ្នាំ នៃកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា។

កម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា ផ្តល់ជូនប្រជាជនកម្ពុជា នូវឱកាសដើម្បីបន្តការសិក្សាថ្នាក់ក្រោយឧត្តមសិក្សានៅតាមសាកលវិទ្យាល័យនានាក្នុងប្រទេសអូស្ត្រាលី។ អាហារូបករណ៍នេះផ្តល់ឱ្យអតីតនិស្សិតកម្ពុជានូវជំនាញ ចំណេះដឹង និងបណ្តាញ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា និងធ្វើឱ្យកិច្ចសហប្រតិបត្តិការរវាងប្រទេសអូស្ត្រាលី និងកម្ពុជា កាន់តែស៊ីជម្រៅ។ ចាប់តាំងពីឆ្នាំ១៩៩៤មក កម្មវិធីនេះបានផ្តល់អាហារូបករណ៍ជាង ១ ០០០កន្លែង ដល់និស្សិតពូកែៗរបស់កម្ពុជា ទៅសិក្សានៅប្រទេសអូស្ត្រាលី។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលី បានមានប្រសាសន៍ថា "អស់រយៈពេលបីទសវត្សរ៍មកហើយ ដែលអាហារូបករណ៍អូស្ត្រាលី ផ្តល់ឱ្យនិស្សិតកម្ពុជានូវឱកាសសិក្សា ព្រមទាំងជួយឱ្យពួកគេ ក្លាយជាកត្តាជំរុញសម្រាប់ការផ្លាស់ប្តូរ ជួយដល់បុគ្គល ស្ថាប័ន គោលនយោបាយ និងការស្រាវជ្រាវនៅទូទាំងប្រទេសកម្ពុជា"។

"មិនថាពួកគេជានិស្សិតទទួលបានអាហារូបករណ៍អូស្ត្រាលី ឬជាអតីតនិស្សិតអូស្ត្រាលីដែលទៅសិក្សាឯកជន និស្សិតកម្ពុជាទាំងអស់ដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យអូស្ត្រាលី បានក្លាយជាអ្នកជំនាញឈានមុខគេក្នុងវិស័យរបស់ពួកគេ ហើយបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយកម្ពុជាអភិវឌ្ឍទៅជាប្រទេសទំនើប សកម្ម និងជោគជ័យ"។

កម្មវិធីអាហារូបករណ៍អូស្ត្រាលី មានមោទនភាពចំពោះវឌ្ឍនភាពនៃបរិយាបន្នរបស់កម្មវិធី។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ចំនួនស្ត្រីដែលទទួលបានអាហារូបករណ៍អូស្ត្រាលីបានកើនឡើង ជាង ៦០ ភាគរយ។ កម្មវិធីនេះក៏បានជួយដល់ជនដែលមានពិការភាពនៅកម្ពុជាមួយចំនួន ឱ្យបន្តក្តីស្រម៉ៃរបស់ពួកគេ ហើយនិស្សិតអាហារូបករណ៍អូស្ត្រាលី ជនជាតិដើមភាគតិចដំបូងគេបង្អស់ពីប្រទេសកម្ពុជា នឹងធ្វើដំណើរទៅកាន់ប្រទេសអូស្ត្រាលី ក្នុងពេលឆាប់ៗខាងមុខនេះ។

*សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា សូមចូលទៅកាន់គេហទំព័រ*

www.australiaawardscambodia.org

*ទំនាក់ទំនងព័ត៌មាន៖* Media.Cambodia@dfat.gov.au